សាលាក្រុងឡុងប៊ីឆ
ការិយាល័យពត៌មានសាធារណៈ
411 W. Ocean Blvd,
Long Beach, CA 90802

CITY OF LONG BEACH

# សេចក្តីប្រកាសពត៌មាន

---

**4/4/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់ សេចក្តីប្រកាសពត៌មាន # 040420

**ប្រធានបទ: សាលាក្រុងឡុងប៊ីឆ ចែករំលែកសេចក្តីណែនាំស្តីពីអនុសាសន៍ CDC សំរាប់ប្រជាពលរដ្ឋទាំងឡាយ ដែលពិសយកការពាក់ ឬគ្របមុខ ក្នុងពេលនៅតាមទីសាធារណៈ**

**ទំនាក់ទំនង:** មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ
562.570.NEWS
jic@longbeach.gov

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - ក្រសួងសុខាភិបាល និងសេវាមនុស្សជាតិក្រុងឡុងប៊ីឆបានបញ្ចេញនូវ ការណែនាំ ស្តីពីអនុសាសន៍ CDC សំរាប់បុគ្គលទាំងអស់អោយពាក់គម្របមុខ ដើម្បីការពារប្រឆាំងនិងជំងឺ COVID-19, ពេលចាកចេញពីផ្ទះរបស់ពួកគេ ដើម្បីចូលរួមក្នុងសកម្មភាពចំបាច់នានា។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “ទោះបីជាអ្នកមិនឃើញមានបង្ហាញនូវរោគសញ្ញាអ្វីសោះក៏ដោយ អ្នក អាចផ្ទុកជំងឺ COVID-19 និងធ្វើអោយមានគ្រោះថ្នាក់ដល់អ្នកដទៃដែលនៅជុំវិញអ្នកបាន,”។ “ពាក់អ្វីសាមញ្ញៗ ដូចជាគម្របក្រណាត់គ្របមុខ នៅពេលដែលអ្នកចេញខាងក្រៅ អាចជួយធ្វើអោយឃឹតនូវអត្រានៃការចំលង និងកាត់បន្ថយនូវការដាក់បន្ទុកបន្ថែមលើមន្ទីរពេទ្យទាំងឡាយរបស់ពួកយើង នៅក្នុងបណ្តាអាទិត្យដែលធ្ងន់ធ្ងរបំផុតខាងមុខ”។

ក្រសួងសុខាភិបាល និងសេវាមនុស្សជាតិក្រុងឡុងប៊ីឆ មិនតម្រូវអោយបុគ្គលម្នាក់ៗពាក់គម្របមុខ ក្នុងពេលនៅតាមទីសាធារណៈឡើយ និងបន្តផ្តល់ដំបូន្មានដល់សហគមន៍ប្រសើរបំផុត និងបុគ្គលម្នាក់ៗ ក្នុងការប្រឆាំងនិងជំងឺ COVID-19 គឺលាងដៃរបស់ពួកយើងអោយបានញឹកញាប់ ជៀសវាងការប៉ះពាល់ភ្នែក ច្រមុះ និងមាត់របស់អ្នក ជាមួយដៃដែលមិនទាន់លាង ជៀសវាងនៅជិតមនុស្សឈឺ និងអនុវត្តរាងកាយនៅឆ្ងាយពីគ្នា ជាពិសេសដោយការនៅផ្ទះ។

វេជ្ជបណ្ឌិត Dr. Anissa Davis មន្រ្តីសុខាភិបាលស៊ីធី មានប្រសាសន៍ថា “យើងសូមបញ្ជាក់ថា ការពាក់គម្របគ្របមុខ មិនមែនសំរាប់ជំនួសអោយការបន្តអនុវត្ត នូវកិច្ចការពារដែលមានភស្តុតាងជាមូលដ្ឋាននោះឡើយ ដូចជាការលាងដៃរបស់អ្នកអោយបានញឹកញាប់ និងរាងកាយនៅឆ្ងាយពីគេ,”។ “ការគ្របមុខ អាចមានប្រយោជន៍ នៅតាមទីសាធារណៈដែលទីនោះមានការលំបាកក្នុងការថែរក្សា ឬអនុវត្តនូវវិធានការណ៍រាងកាយនៅឆ្ងាយពីគេ ដូចជា នៅឱសថស្ថាន ឬហាងគ្រឿងទេសនានា”។

ក្រសួងសុខាភិបាលសាធារណៈរដ្ឋកាលីហ្វ័រញ៉ា កំណត់ថាគម្របមុខ គឺជាសំភារៈនានា ដូចជាកប្បាស សូត្រ ឬក្រណាត់លេនីន ដែលគ្របមាត់ និងច្រមុះ។ គម្រប អាចជាវត្ថុដែលធ្វើនៅផ្ទះ ឬបានច្នៃប្រឌិតពីរបស់របរប្រើប្រាស់ប្រចាំថ្ងៃ ដូចជាក្រម៉ា កូនកន្សែងដៃ អាវយឺត និងកន្សែង។ ឧបករណ៍ដកដង្ហើម N95 និងម៉ាស់វះកាត់ មិនត្រូវបានណែនាំអោយទិញជា

សាធារណៈឡើយ។ សំភារៈចាំបាច់ទាំងអស់នេះ គឺកំពុងមានការខ្វះខាតនូវការផ្គត់ផ្គង់នៅទូទាំងប្រទេស ហើយត្រូវតែអភិរក្សសំរាប់បុគ្គលិកថែទាំសុខភាព និងអ្នកឆ្លើយតបដំបូងទាំងឡាយ។

មន្ត្រីស៊ីធី រំលឹកដល់ប្រជាពលរដ្ឋទាំងអស់ អោយបន្តប្រកាន់ខ្ជាប់នូវបទបញ្ជា ឬសណ្តាប់ធ្នាប់ "មានសុវត្ថិភាពជាងពេលនៅផ្ទះ" និងចេញពីផ្ទះរបស់ពួកគេ សំរាប់សកម្មភាពចាំបាច់នានាតែប៉ុណ្ណោះ ដូចជាការទៅយកម្ហូប ចូលរួមការណាត់ជួបវេជ្ជសាស្រ្ត ការហាត់ប្រាណ បណ្តើរសត្វចិញ្ចឹមរបស់អ្នក ឬថែទាំមនុស្សដែលអ្នកស្រឡាញ់ណាម្នាក់។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីចកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីច តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.